ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទវគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ និងបើកវគ្គគ្រូលែនកម្រិតមូលដ្ឋានទី២ ស្តីពីភាពជាអ្នកដឹកនាំ
**នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤**

សូមគោរព ៖

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងគ្រួយៗសិក្ខាកាម ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងពិធីបិទវគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋាន ស្តីពី "ភាពជាអ្នកដឹកនាំ" នាពេលនេះ ។ ដោយមានសំណូមពរពីគណៈកម្មាធិការរៀបចំវគ្គ ខ្ញុំសូមប្រសិទ្ធនាមវគ្គបណ្តុះបណ្តាលនេះថា "វគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ ស្តីពីភាពជាអ្នកដឹកនាំ" សម្រាប់ពង្រឹងសមត្ថភាពជាអ្នកដឹកនាំដល់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើង ។ នៅឆ្នាំនេះ យើងរៀបចំពិធីបិទវគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ ដំណាលគ្នាក្នុងថ្ងៃតែមួយជាមួយនឹងពិធីបើកវគ្គគ្រូលែនកម្រិតមូលដ្ឋានទី២ ស្តីពីភាពជាអ្នកដឹកនាំផងដែរ ។ ការរៀបចំបែបនេះ គឺដើម្បីបង្កបរិយាកាសឱ្យមន្ត្រីសិក្ខាកាមវគ្គទី១និងវគ្គទី២បានជួបប្រាស្រ័យគ្នា ផ្លាស់ប្តូរយោបល់គ្នា ចែករំលែកបទពិសោធន៍គ្នា និងដើម្បីពង្រឹងបណ្តាញការងារ (networking) ឱ្យកាន់តែល្អប្រសើរនិងមានប្រសិទ្ធភាពថែមទៀត ។

តាមរយៈរបាយការណ៍របស់ លោក ថៃ សភា ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា វគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ ស្តីពីភាពជាអ្នកដឹកនាំ រយៈពេល ៣ខែនេះ បានប្រព្រឹត្តទៅយ៉ាងសកម្មនិងប្រកបដោយជោគជ័យ ហើយបានផ្តល់ចំណេះដឹងទាក់ទងនឹងទស្សនាទានជាមូលដ្ឋានស្តីពីភាពជាអ្នកដឹកនាំ យល់ដឹងពីទស្សនវិស័យនិងមុខងារ-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ វិធីសាស្ត្រនិងរបៀបប្រាស្រ័យទាក់ទងជាមួយថ្នាក់ដឹកនាំ ឥរិយាបថនិងប្រសិទ្ធភាពនៃការងារបុគ្គលនិងក្រុមជាដើម ។ ខ្ញុំសូមចូលរួមអបអរសាទរចំពោះលទ្ធផលដែលក្មួយៗទាំងអស់បានខិតខំប្រឹងប្រែងសម្រេចបានប្រកប



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដោយជោគជ័យនាពេលនេះ ។ ចំណេះដឹងទាំងនេះ គឺជាប្រភពទុននិងជាយានមួយយ៉ាងសំខាន់សម្រាប់បំពេញការងារនិងជីវភាពប្រចាំថ្ងៃរបស់ក្មួយៗ ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក Faisal Ahmed តំណាងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា លោក Arnaud de Villepoix ជំនាញការទូទៅរបស់ IMF ប្រចាំធនាគារជាតិនៃកម្ពុជា លោកជំទាវទេសាភិបាលរង ថ្នាក់ដឹកនាំ និងមន្ត្រីឧទ្ទេសនាមរបស់យើងទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចែករំលែកចំណេះដឹងនិងបទពិសោធន៍ល្អៗជូនដល់មន្ត្រីធនាគារជាតិនៃកម្ពុជាយើង ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី!**

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ជម្រាបពីមូលហេតុដែលខ្ញុំជ្រើសរើសយកពាក្យ "គូលែន" មកប្រសិទ្ធនាមឱ្យឈ្មោះវគ្គបណ្តុះបណ្តាលនេះបន្តិច ។ ពាក្យ "គូលែន" ខ្ញុំមិនសំដៅដល់ឈ្មោះផ្លែឈើនោះទេ ប៉ុន្តែខ្ញុំចង់រំលឹកពីទីតាំងប្រវត្តិសាស្ត្រនិងវីរភាពរបស់ព្រះមហាក្សត្រខ្មែរដែលមានភាពជាអ្នកដឹកនាំដ៏ប៉ិនប្រសប់នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើងកន្លងមក គឺ៖

១/- ឈ្មោះភ្នំគូលែន ស្ថិតក្នុងខេត្តសៀមរាប ទឹកដីប្រវត្តិសាស្ត្រកម្ពុជាយើង ។ ភ្នំគូលែននេះ មានឈ្មោះដើមថា *មហិន្ទ្រពិត* ដែលជាកន្លែងដែលអតីតព្រះមហាវីរក្សត្រខ្មែរ ព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) បានជ្រើសរើសយកជាទីតាំងសម្រាប់ប្រារព្ធពិធីទេវរាជ និងដឹកនាំចលនាស្នេហាជាតិ ដើម្បីបង្រួបបង្រួមទឹកដីនិងដណ្តើមឯកភាពជាតិឡើងវិញ បន្ទាប់ពីប្រទេសកម្ពុជាបានចុះទន់ខ្សោយនិងបែកចេញជាពីរ គឺ*អាណាចក្រចេនឡាដីគោក និងចេនឡាដីទឹក* ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជ្វាក្នុងចុងសតវត្សរ៍ទី៨ ។

២/- ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីទីតាំងដែលជានិមិត្តរូបនៃការខិតខំប្រឹងប្រែងកសាងកម្លាំង ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប៉ិនប្រសប់របស់ព្រះបាទជ័យវរ្ម័នទី២ ដែលបានបង្រួបបង្រួមទឹកដីដែលបែកបាក់ មកឯកភាពជាតិតែមួយ និងជាចំណុចចាប់ផ្តើមនៃសម័យអង្គរដ៏រុងរឿងនៃប្រវត្តិសាស្ត្រកម្ពុជាយើង *និង*

៣/- បង្ហាញពីភាពម្ចាស់ការរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងខិតខំរៀបចំបណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្សដែលជាកម្លាំងបន្តវេនដោយខ្លួនឯង ដើម្បីរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជាឱ្យកាន់តែរីកចម្រើន និងមានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់និងពិភពលោកថែមទៀត ។

តើក្មួយៗដឹងទេ ប្រទេសជាតិមួយមានការឯកភាពជាតិនិងការអភិវឌ្ឍរីកចម្រើនរុងរឿង គឺកើតឡើងដោយសារការដឹកនាំដ៏ប៉ិនប្រសប់និងឈ្លាសវៃរបស់ថ្នាក់ដឹកនាំនៃប្រទេសនោះ ។ ជាក់ស្តែង បើតាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើងថ្មីៗនេះ ក្មួយៗបានដឹងនិងបានឃើញហើយ នៅឆ្នាំ១៩៩៨ អនុវត្តតាមនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រទេសកម្ពុជាឱ្យមានសន្តិភាពនៅទូទាំងប្រទេស ១០០ភាគរយ និងមានការអភិវឌ្ឍលើគ្រប់វិស័យ ហើយមានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់និងពិភពលោក ។ នេះគឺជាមេរៀន Leadership មួយយ៉ាងសំខាន់ផងដែរ ដែលបង្ហាញឱ្យប្រជាជនកម្ពុជាយល់ច្បាស់ពីវីរភាពអង់អាចក្លាហានរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងវីរជនស្នេហាជាតិជាច្រើនរូបទៀត ដែលបានរំដោះប្រទេសនិងសង្គ្រោះប្រជាជនកម្ពុជាឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ហើយបានដឹកនាំប្រទេសឆ្ពោះទៅរកសន្តិភាពនិងការអភិវឌ្ឍលើគ្រប់វិស័យរហូតដល់សព្វថ្ងៃនេះ ។ បទពិសោធន៍និងមេរៀននៃប្រវត្តិសាស្ត្របានបង្រៀនយើងយ៉ាងច្រើនលើគ្រប់ទិដ្ឋភាព ក្នុងនោះក៏មានភាពជាអ្នកដឹកនាំច្រើនណាស់ដែរ នៅតាមដំណាក់កាលប្រវត្តិសាស្ត្រនីមួយៗ ។ ពេលវេលានិងព្រឹត្តិការណ៍ជាអ្នកបង្កើតវីរបុរសនិងប្រវត្តិសាស្ត្រ ។ តាមរយៈព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងវីរជននោះ អាចឆ្លុះបញ្ចាំងឱ្យយើងឃើញពីភាពជាអ្នកដឹកនាំបាន ។ ដំណាក់កាលខ្លះនាំមកនូវភាពរុងរឿង និងដំណាក់កាលខ្លះនាំឱ្យប្រទេសជាតិវិនាសអន្តរាយ ឧទាហរណ៍ជាក់ស្តែង គឺដំណាក់កាលនៃរបបប្រល័យពូជសាសន៍ប៉ុលពត ។ សូមក្មួយៗទាំងអស់ចងចាំទុកនិងរួមចំណែកការពារសមិទ្ធផលសង្គមជាតិដែលយើងបានខិតខំកសាងឡើង និងជៀសវាងកុំឱ្យប្រវត្តិសាស្ត្រជាន់ដានចាស់ ដូចពាក្យមួយថា "Don't let our history repeats itself" ។

ការកសាងធនធានមនុស្ស គឺជាគន្លឹះយ៉ាងសំខាន់សម្រាប់ធានានិរន្តរភាពស្ថាប័ន និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនឈានឡើង ។ ការអភិវឌ្ឍធនធានមនុស្ស ចាំបាច់ត្រូវធ្វើជាប់ជាប្រចាំ ដូចភ្លៀងរលឹម សម្រាប់ធានានូវនិរន្តភាពការងាររបស់យើង ។ កន្លងមក យើងបាននិងកំពុងបណ្តុះបណ្តាលមន្ត្រីបុគ្គលិកយើងលើជំនាញឯកទេសកម្មខាងត្រួតពិនិត្យ បញ្ញត្តិកម្ម សវនកម្ម គណនេយ្យ ការរៀបចំគោលនយោបាយរូបិយវត្ថុ ការវិភាគសេដ្ឋកិច្ច និងការគ្រប់គ្រងទុនបម្រុងអន្តរជាតិជាដើម ក្រោមរូបភាពជា In-house trainings និងនៅក្រៅប្រទេស ដូចជា ការចូលរួមសិក្ខាសាលានិងកិច្ចប្រជុំនានាជាដើម ។ ការផ្តួចផ្តើមគំនិតរៀបចំវគ្គគូលែនកម្រិតមូលដ្ឋានស្តីពីភាពជាអ្នកដឹកនាំនេះឡើង ស្របពេលជាមួយនឹងនិន្នាការរបស់ធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ កំពុងយកចិត្តទុកដាក់បណ្តុះបណ្តាលមន្ត្រីរបស់ខ្លួនដែរ ក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលមន្ត្រីបុគ្គលិកឱ្យក្លាយជា

អ្នកការពារនិងជាកម្លាំងបន្តវេនសម្រាប់ស្ថាប័នប្រកបដោយប្រសិទ្ធភាព ដែលហ៊ានតស៊ូលះបង់ជម្នះនឹងការលំបាកគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុនិងអាយុជីវិតស្ថាប័ននៅគ្រប់កាលៈទេសៈផងដែរ ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី!**

ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ យើងខិតខំបណ្តុះបណ្តាលមន្ត្រីយើងច្រើនណាស់ លើគ្រប់ផ្នែកនិងគ្រប់រូបភាព ប៉ុន្តែទោះបីជាយើងបានខិតខំបណ្តុះបណ្តាលមន្ត្រីបុគ្គលិកជាប់ជាប្រចាំក៏ដោយ ក៏យើងនៅតែទទួលស្គាល់ថា ធនាគារជាតិនៃកម្ពុជាយើងមិនទាន់មានធនធានមនុស្សគ្រប់គ្រាន់នៅឡើយទេ បើប្រៀបធៀបនឹងទំហំការងាររបស់យើងបច្ចុប្បន្ន ដែលចេះតែអភិវឌ្ឍរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ។ ជាក់ស្តែង នៅចុងឆ្នាំ២០១០ កន្លងមក ដើម្បីឆ្លើយតបចំពោះការអភិវឌ្ឍរីកចម្រើននេះ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានសម្រេចកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងនិងចាត់តាំងរបស់ធនាគារជាតិនៃកម្ពុជា ដោយបង្កើតឱ្យមានអគ្គនាយកដ្ឋានចំនួន ៥ គឺ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គបេឡា និងអគ្គាធិការដ្ឋាន ឱ្យស្របតាមទំហំការងារនិងស្ថានភាពអភិវឌ្ឍរីកចម្រើននៃវិស័យធនាគារនិងសេដ្ឋកិច្ចនៃប្រទេសកម្ពុជាយើង ។ ការរីកចម្រើននេះ គឺយើងត្រូវការធនធានមនុស្សបន្ថែមជានិច្ច ដើម្បីគាំទ្រប្រតិបត្តិការធនាគារកណ្តាលនិងការអភិវឌ្ឍឈានឡើងទាំងនេះ ។

ទាក់ទងនឹងការធានានិរន្តរភាពការងារធនាគារជាតិនៃកម្ពុជាឱ្យប្រព្រឹត្តទៅដោយប្រសិទ្ធភាព ខ្ញុំសូមលើកយកពីមុខងារសំខាន់ៗរបស់ធនាគារកណ្តាលចំនួន២ មកជម្រាបជូន គឺ ទី១/- ការថែរក្សានូវតម្លៃ "រូបិយវត្ថុជាតិ" ជាភារកិច្ចស្នូលរបស់យើងទាក់ទងនឹងការកំណត់និងដឹកនាំគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា និងទី២/- តួនាទីធានាឱ្យមានស្ថិរភាពនិងការអភិវឌ្ឍនៃប្រព័ន្ធធនាគារទាំងមូល ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ។ ដើម្បីអនុវត្តភារកិច្ចនេះឱ្យបានជោគជ័យនិងមានប្រសិទ្ធភាពថែមទៀត គឺអាស្រ័យលើកត្តាធនធានមនុស្ស និងសមត្ថភាពចាត់ចែងការ ដើម្បីដឹកនាំនិងគ្រប់គ្រងស្ថាប័នរបស់យើងថា តើយើងត្រូវគ្រប់គ្រងធនធានមនុស្សនិងបែងចែកធនធានមនុស្សរបស់យើងឱ្យចំគោលដៅ ប្រកបដោយប្រសិទ្ធភាពបែបណា? ។ មានន័យថា តើយើងត្រូវរៀបចំនិងចាត់តាំងមន្ត្រីបុគ្គលិកយើងនៅតាមនាយកដ្ឋាននិងអង្គភាពជំនាញនីមួយៗ ឱ្យស្របតាមតម្រូវការនិងទំហំការងារដោយរបៀបណា? ។ តាមរយៈបទពិសោធន៍ក្នុងដំណាក់កាលសេដ្ឋកិច្ចកំពុងទទួលរងនូវវិបត្តិឆ្នាំ១៩៩៧ ក៏ដូចជានៅឆ្នាំ២០០៨ បានបង្ហាញ

ឱ្យយើងឃើញយ៉ាងច្បាស់ថាការរៀបចំនិងអនុវត្តយុទ្ធសាស្ត្រដើម្បីដោះស្រាយវិបត្តិ កុំឱ្យមានឥទ្ធិពលខ្លាំងមកលើសេដ្ឋកិច្ចនិងសង្គមពេលនោះ មានទំនាក់ទំនងគ្នារវាងសមត្ថភាពឯកទេសនិងតួនាទីនៃភាពជាអ្នកដឹកនាំរបស់មន្ត្រីជំនាញនិងថ្នាក់ដឹកនាំនៃស្ថាប័ននីមួយៗ ជាពិសេស ធនាគារកណ្តាលដែលជាអាជ្ញាធរអាណាព្យាបាលលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីចាត់វិធានការប្រុងប្រយ័ត្នពង្រឹងសុខភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ឱ្យប្រព្រឹត្តទៅដោយសុវត្ថិភាព និងមានប្រសិទ្ធភាព ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី គ្រូឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី!**

ដោយយល់ឃើញពីសារៈសំខាន់នៃការគ្រប់គ្រងធនធានមនុស្ស និងការបណ្តុះបណ្តាលកម្លាំងបន្តវេនរបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ពេលបច្ចុប្បន្ននិងទៅអនាគត ខ្ញុំសូមឱ្យគណៈកម្មាធិការរៀបចំវគ្គសិក្សា ជាពិសេស នាយកដ្ឋានបុគ្គលិក បន្តរៀបចំវគ្គនេះជារៀងរាល់ឆ្នាំ និងរៀបចំបើកវគ្គបាគងស្តីពីការត្រួតពិនិត្យធនាគារបន្តទៀត ដើម្បីឱ្យមន្ត្រីវ័យក្មេងរបស់យើងបានសិក្សាស្វែងយល់ពីតួនាទីធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការប្រែប្រួលថ្មីៗនៃនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ និងគោលការណ៍ត្រួតពិនិត្យថ្មីៗរបស់គណៈកម្មាធិការទីក្រុងបាសែល ។

បន្ទាប់ពីវគ្គគូលែនកម្រិតមូលដ្ឋានទី១ ត្រូវបានបញ្ចប់ វគ្គគូលែនកម្រិតមូលដ្ឋានទី២ ស្តីពីភាពអ្នកដឹកនាំ នឹងត្រូវចាប់ផ្តើមនៅពេលបន្តិចទៀតនៅក្នុងថ្ងៃនេះផងដែរ ខ្ញុំសូមឱ្យក្មួយៗទាំងអស់ខិតខំត្រងត្រាប់ស្តាប់បទឧទ្ទេសនាម និងយកចំណេះដឹងដែលទទួលបានទៅអនុវត្តនិងពង្រឹងការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាព សំដៅរួមចំណែកអភិវឌ្ឍធនាគារយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ២០១១-២០២០ របស់រាជរដ្ឋាភិបាល ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗទាំងអស់ ដែលមានវត្តមាននៅទីនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបិទវគ្គគូលែនកម្រិតមូលដ្ឋានទី១ និងប្រកាសបើកវគ្គគូលែនកម្រិតមូលដ្ឋានទី២ ស្តីពីភាពជាអ្នកដឹកនាំ ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**